ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩

## សេចក្តីប្រកាសព័ត៌មាន

## មានភ្ញៀវជាង ១២.០០០នាក់ បានចូលរួមសវនាការ ឌុច

នៅថ្ងៃពុធ ទី២២ ខែកក្កដា ឆ្នាំ២០០៩ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក)បានទទួលអ្នកចូលរួមចំនួន១២.០០០នាក់ ក្នុងសវនាការសំណុំរឿង០០១ ប្រឆាំង កាំង ហ្កិចអ៊ាវ ហៅឌុច ដែលចាប់ផ្តើមដំបូងនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩។

នៅក្នុងរយៈប៉ុន្មានខែដំបូង ផ្នែកកិច្ចការសាធារណៈបានពង្រឹងកិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើនទាំងសកម្មភាពផ្សព្វផ្សាយនិងការចូលរួមរបស់អ្នកទស្សនានៅក្នុងតុលាការ។ ដោយសារការផ្សព្វផ្សាយប្រកបដោយប្រសិទ្ធភាពតាមការដៅទុកតាមរយៈការប្រើការផ្សព្វផ្សាយតាមវិទ្យុ តុលាការមានលទ្ធភាពផ្តល់ព័ត៌មានយ៉ាងទូលំទូលាយអំពីរបៀបចូលរួមសវនាការ។ អ.វ.ត.ក ផ្តល់ការដឹកជញ្ជូនតាមរថយន្តក្រុងដោយឥតគិតថ្លៃទៅវិញទៅមកពីខេត្តមកតុលាការ ពីតុលាការទៅខេត្ត ចំពោះប្រជាជនមួយក្រុមមានគ្នាចំនួន៣០នាក់ ឬ៣០នាក់ជាងដែលបានសម្តែងចំណាប់អារម្មណ៍ចូលរួមសវនាការ ឌុច។

ក្នុងរយៈពេល៤ខែ នៃសវនាការ ឌុច នៅតែមានអ្នកចាប់អារម្មណ៍ដ៏ច្រើនមកទស្សនាតុលាការ។ រថយន្តក្រុងត្រូវបានរៀបចំរួចជាស្រេចសម្រាប់នាំភ្ញៀវចំនួន ១.០០០ នាក់ មកស្តាប់សវនាការនៅពីរសប្តាហ៍ខាងមុខនេះ។ តំណាងអ្នកភូមិនិងសហគមន៍ដែលមានបំណងប្រាថ្នាចង់ទស្សនាសវនាការអាចទាក់ទងមន្ត្រីព័ត៌មានគឺលោក ឌឹម សុវណ្ណរុំ (លេខទូរស័ព្ទ ០១២ ៤៨៨ ០៩៤) ឬជំនួយការផ្សព្វផ្សាយលោក ជិន ហែមវិចិត្រ (លេខទូរស័ព្ទ ០១២ ៦៩៦ ២២០)។

គិតមកត្រឹមថ្ងៃអង្គារ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ នេះ មានភ្ញៀវចំនួន ១១.៩៩០នាក់ បានចូលរួមក្នុងសវនាការ ឌុច ចាប់តាំងពីការចាប់ផ្តើមដំបូងនៅថ្ងៃទី៣០ ខែមីនា។ ចំនួននេះគិតជាមធ្យមគឺមានភ្ញៀវចំនួន ២៤៩ នាក់ក្នុងមួយថ្ងៃ។

| កាលបរិច្ឆេទសវនាការ<br>(ប្រចាំសប្តាហ៍) | ចំនួនភ្ញៀវសរុប<br>(ប្រចាំសប្តាហ៍) |
|---|---:|
| 30/03/09-01/04/09 | 1176 |
| 06/04/09-09/04/09 | 623 |
| 20/04/09-23/04/09 | 642 |
| 27/04/09-30/04/09 | 742 |
| 18/05/09-21/05/09 | 575 |
| 25/05/09-28/05/09 | 560 |
| 08/06/09-10/06/09 | 415 |
| 15/06/09-17/06/09 | 621 |
| 22/06/09-25/06/09 | 860 |
| 29/06/09-02/07/09 | 1899 |
| 06/07/09-09/07/09 | 1553 |
| 13/07/09-16/07/09 | 1504 |
| 20/07/09-21/07/09 | 820 |
| **សរុបរួមគិតត្រឹមថ្ងៃអង្គារទី២១ខែកក្កដាឆ្នាំ២០០៩** | 11990 |

រូបភាពពីដំណើរការនីតិវិធីតុលាការថ្ងៃនេះអាចរកបាន៖

http://www.flickr.com/photos/krtribunal/sets/72157621772525656


សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**រាជ សម្បត្តិ**

ប្រធានកិច្ចការសាធារណៈ អ.វ.ត.ក

ទូរស័ព្ទ៖ +៨៥៥-១២ ៤៨៨ ១៥៦

ទូរសារ៖ +៨៥៥-២៣ ២១៩ ៨៤១

អ៊ីមែល៖ reach.sambath@eccc.gov.kh

**ឌីម សុវណ្ណារុំ**

មន្ត្រីព័ត៌មាន អ.វ.ត.ក

ទូរស័ព្ទចល័ត៖ +៨៥៥-១២ ៤៨៨ ០៩៤

ទូរស័ព្ទអចល័ត៖ +៨៥៥-២៣ ២១៩ ៨១៤

អ៊ីមែល៖ dim.sovannarom@eccc.gov.kh

Lars Olsen
មន្ត្រីទំនាក់ទំនងច្បាប់ អ.វ.ត.ក
ទូរស័ព្ទ៖ +៨៥៥-១២ ៤៨៨ ០២៣
ទូរស័ព្ទអចល័ត៖ +៨៥៥-២៣ ២១៩ ៨១៤ ext.៦១៦៩
អ៊ីមែល៖ olsenl@un.org